# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ខេត្តស្វាយរៀង**
**ស្រុករំដួល**
**ឃុំពងទឹក**
**លេខ:០០៤ដក**

# ដីកា

## ស្តីពី

### " ការបង្ការ និងទប់ស្កាត់អំពើហិង្សារួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង "

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ២០០១
- បានឃើញអនុក្រិត្យលេខ២២ អនក/បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ឲ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ ពងទឹក ស្តីពីការបង្ការនិងទប់ស្កាត់អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៦ ។
- យោងលទ្ធផលសិក្ខាសាលាស្តីពី"វិធានការរួមស្តីពីការបង្ការនិងទប់ស្កាត់អំពើហិង្សាលើដៃគូស្និទ្ធស្នាលដែលជាប់ពាក់ព័ន្ធនឹងគ្រឿងស្រវឹង" ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៦ ។

ដោយមើលឃើញថាបញ្ហាដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងស្រវឹងបានធ្វើឲ្យមានអំពើហិង្សា ភាពឥតសណ្តាប់ធ្នាប់ អសន្តិសុខ ភាពក្រីក្រ និង ប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋជារួមក្នុងឃុំ ពងទឹក ដូច្នេះក្រុមប្រឹក្សាឃុំ ពងទឹក

## សម្រេច

**ប្រការ១:** ដីកានេះមានគោលបំណងការពារសិទ្ធិស្ត្រីសិទ្ធិកុមារនិងបង្ការអំពើហិង្សាលើដៃគូស្និទ្ធស្នាលព្រមទាំងលើកកម្ពស់សុខុមាលភាពនិងប្រាក់ចំណូលប្រជាពលរដ្ឋក៏ដូចជារក្សាសន្តិសុខសណ្តាប់ធ្នាប់ និង សុវត្ថិភាពក្នុងឃុំ ពងទឹក ទាំងមូល ។

**ប្រការ២:** ដីកានេះមានវិសាលភាពអនុវត្តទៅលើ អ្នកប្រើប្រាស់គ្រឿងស្រវឹងដែលបង្កបញ្ហា ឬបង្ករការរំខាន ឬបង្កហិង្សានានារួមទាំងទៅលើដៃគូស្និទ្ធស្នាលដូចជាប្តីប្រពន្ធ សង្សា ព្រមទាំងអ្នកផលិត អ្នកលក់ផលិតផលគ្រឿងស្រវឹងទៅឲ្យជនឬនៅទីកន្លែងមួយចំនួនក្នុងឃុំពងទឹក ដែលបានកំណត់ក្នុងដីកានេះ ។

**ប្រការ៣:** ហាមប្រើឲ្យទិញ ឬលក់គ្រឿងស្រវឹងឲ្យក្មេងអាយុក្រោម១៨ឆ្នាំ ។ ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី១០០០០៛ (មួយម៉ឺនរៀល)ទៅ ២០០០០៛ (ពីរម៉ឺនរៀល) ។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង ។

**ប្រការ៤៖**រាល់ការផលិតឬលក់គ្រឿងស្រវឹងត្រូវមានការអនុញ្ញាត និង ចេញលិខិតដោយមេឃុំ ហើយមានការត្រួតពិនិត្យពីអ្នកជំនាញរបស់ក្រសួងសុខាភិបាល ។

ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះត្រូវផាកពិន័យជាប្រាក់ពី២០,០០០៛ (បីម៉ឺនរៀល) ទៅ ៥០,០០០៛ (ប្រាំម៉ឺនរៀល)។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង ក្នុងករណីពិន័យបីលើកហើយនៅមិនរាងចាលត្រូវបញ្ឈប់ការផលិត និង ការលក់ដូរគ្រឿងស្រវឹងគ្រប់ប្រភេទ ។

**ប្រការ៥៖**អ្នកដែលប្រើប្រាស់គ្រឿងស្រវឹងហើយដើរស្រែកឡូឡា ឬ ប្រើឧបករណ៍បំពងសំឡេងរំខានដល់អ្នកដទៃចាប់ពីម៉ោង១១:០០នាទីយប់តទៅត្រូវផាកពិន័យជាទឹកប្រាក់ពី៥០,០០០៛(ប្រាំម៉ឺនរៀល)ទៅ១០០,០០០៛ (មួយសែនរៀល ) ។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង ។

**ប្រការ៦៖**មិនអនុញ្ញាតអោយមានការលក់ផលិតផលគ្រឿងស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹងគ្រប់ប្រភេទនៅ តាមបរិវេណវត្តអារាម សាលាឆទាន សាលារៀន មណ្ឌលសុខភាព សាលាឃុំ ប៉ុស្តិ៍រដ្ឋបាល ។

ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី២០,០០០៛ (ពីរម៉ឺនរៀល)ទៅ៤០,០០០៛(បួនម៉ឺនរៀល)។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង ។

**ប្រការ៧៖** អ្នកប្រើប្រាស់គ្រឿងស្រវឹង ហើយបង្កហិង្សាដែលទាក់ទងផ្លូវចិត្ត និង ផ្លូវសេដ្ឋកិច្ច(ជេរប្រមាថអ្នកដទៃ , បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ) ត្រូវផាកពិន័យជាទឹកប្រាក់ពី១០០,០០០៛(ដប់ម៉ឺនរៀល)ទៅ ១៥០,០០០៛ (មួយសែនប្រាំម៉ឺនរៀល) ព្រមទាំងសងជាសំណងដល់ការខូចខាតសម្ភារៈ ។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង ។ ចំពោះបទឧក្រិដ្ឋត្រូវចាត់វិធានការទៅតាមផ្លូវច្បាប់ ។

**ប្រការ៨៖** មិនត្រូវលក់ឲ្យ ឬ ទិញគ្រឿងស្រវឹង ចំពោះអ្នកដែលស្ថិតក្នុងស្ថានភាពស្រវឹងជោគជាំ ។ ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី១០,០០០៛ ( មួយម៉ឺនរៀល) ទៅ២០,០០០៛ (ពីរម៉ឺនរៀល) ។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ទ្វេដង ។ ចំពោះអ្នកបើកបរហួសល្បឿនកំណត់ក្រោមឥទ្ធិពលនៃការប្រើប្រាស់គ្រឿងស្រវឹងបើមានបញ្ហាប៉ះឬបុកអ្នកដទៃប្រជាពលរដ្ឋក្នុងឃុំទាំងមូលមានសិទ្ធិស្ទាក់ចាប់រួចបញ្ជូនទៅសមត្ថកិច្ច ។

**ប្រការ៩៖** រាល់ការផាកពិន័យ និង ការចុះត្រួតពិនិត្យជាតួនាទីរបស់ក្រុមប្រឹក្សាឃុំ និង នគរបាលប៉ុស្តិ៍រដ្ឋបាល ហើយថវិកាដែលផាកបាននោះត្រូវរក្សាទុកនៅសាលាឃុំដើម្បីចាត់ចែងក្នុងការបើកវគ្គផ្សព្វផ្សាយពីផលប៉ះពាល់ការប្រើប្រាស់គ្រឿងស្រវឹង និង ចាត់ចែងក្នុងការលើកទឹកចិត្តដល់អ្នកដែលឈប់ប្រើប្រាស់គ្រឿងស្រវឹងជាស្ថាពរ ។

**ប្រការ១០៖**អជ្ញាធរមូលដ្ឋានភូមិ ឃុំ ប៉ូលីសប៉ុស្តិ៍រដ្ឋបាល គ្រូបង្រៀន បុគ្គលិកសុខាភិបាល យុវជន គណៈកម្មការអាចារ្យ និង ព្រះសង្ឃត្រូវចូលរួមផ្សព្វផ្សាយដល់ប្រជាជនក្នុងសហគមន៍ឲ្យបានជ្រួតជ្រាប ។

**ប្រការ១១៖** ដីកានេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ពងទឹក ,ថ្ងៃទី១២ ខែ មីនា ឆ្នាំ២០១៦

**មេឃុំពងទឹក**